ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ និងអបអរសាទរ

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវការអបអរសាទរ និងសប្បាយរីករាយយ៉ាងក្រៃលែងចំពោះសមិទ្ធផលជាប្រវត្តិសាស្ត្រដែលកម្ពុជាទទួលបានដំណក់ប្រេងជាលើកដំបូង ដែលជាការចាប់ផ្តើមដ៏សំខាន់បំផុតសម្រាប់ប្រទេសយើងឈានឆ្ពោះទៅកាន់ខឿនឧស្សាហកម្មឧស្ម័ន និងថាមពល។ នេះគឺជាពរជ័យសម្រាប់ប្រទេសជាតិ និងប្រជាជនកម្ពុជាយើង។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរពដឹងគុណដ៏ស្មោះអស់ពីដួងចិត្តចំពោះគំរូវីរភាពដ៏ឆ្នើមរបស់ **សម្តេចតេជោ** ដែលបានរួមចំណែកតស៊ូ រំដោះប្រទេសជាតិ ស្វះស្វែងរកសន្តិភាព បង្រួបបង្រួមជាតិ កសាង និងអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនដូចបច្ចុប្បន្ន។ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាសម្រេចនូវសមិទ្ធផលដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ ថែរក្សាបាននូវសុខសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដីដ៏រឹងមាំ ឯកភាពជាតិ ស្ថិរភាពជាតិ និងការរីកចម្រើនជឿនលឿនលើគ្រប់វិស័យ។

តាងនាមឲ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ យើងខ្ញុំសូមអរគុណដល់សុខសន្តិភាព និងនយោបាយ **ឈ្នះ ឈ្នះ** របស់ **សម្តេចតេជោ** ដែលបានដឹកនាំនាវាកម្ពុជាទទួលបាននូវកិត្យានុភាពដ៏ស័ក្តិសមទាំងក្នុងក្របខណ្ឌតំបន់ និងលើឆាកអន្តរជាតិ។

យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមប្រោសប្រទានជូន **សម្តេចអគ្គមហាសេនាបតីតេជោ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត បុត្រា បុត្រី និងចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ និង ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងការរាប់អានដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃចន្ទ ១៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh